# ហាងទីផ្សារកសិកផលធម្មជាតិ (NAP) សាខាថ្មី

ទីផ្សារកសិផលធម្មជាតិបានបង្កើតសាខារបស់ខ្លួនមួយទៀតហើយកាលពីថ្ងៃ ១៨ ខែ ០៨ ឆ្នាំ ២០០៨ ។ ទីផ្សារនេះ ស្ថិតនៅទីតាំងផ្ទះលេខ៦៧ ផ្លូវ ២៣០ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ។ នេះជាខាទី ២ ហើយដែលសហគ្រាសសង្គមសេដាកបង្កើតឡើង បន្ទាប់ពីសាខាទី ១ ត្រូវបានបើកលក់កាលពី ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នៅផ្ទះលេខ ១៣ ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ៣ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ដើម្បីបំរើលក់ផលិតផលកសិកម្មដែលមិនប្រើប្រាស់សាធាតុគីមី ជាពិសេស ថ្នាំពុល និងជីគីមី ។ ផលិតផលលក់នៅក្នុងផ្សារកសិផលធម្មជាតិរួមមាន អង្ករ បន្លែ ផ្លែឈើ សាច់មាន់ ស្រាស ស្ករត្នោត ទឹកឃ្មុំ និងគ្រឿងទេសផ្សេងៗ ។ ទន្ទឹមនេះទីផ្សារក៏មានលក់ផលិតផលក្នុងស្រុករបស់ក្រុមហ៊ុនផ្សេងៗទៀតផងដែរ ។

គួររំលឹកថាទីផ្សារកសិផលធម្មជាតិ គឺជាទីផ្សារ បង្កើតឡើងដោយអង្គការ សេដាក ចាប់តាំងពីឆ្នាំ ២០០៤ ក្នុងគោលបំណង ជួយអោយកសិករអាចលក់ផលិតផលបានតម្លៃថ្លៃសមរម្យ និងផ្គត់ផ្គង់ស្បៀងប្រកបដោយសុវត្ថិភាពដល់អតិថិជន និងចូលរួមចំណែកលើកតំកើនសុខភាពរបស់អតិថិជន និងបរិស្ថាន ។ ទីផ្សារគ្រោងបង្កើតអោយបានច្រើនសាខា បន្ថែមនៅភ្នំពេញ បណ្តាខេត្តសំខាន់ៗ ដូចជា បាត់ដំបង កំពង់ចាម សៀមរាប ។ល។




គោលការណ៍ និងគុណតម្លៃរបស់កសិផលធម្មជាតិមានដូចខាងក្រោម:

- សុវត្ថិភាពចំណីអាហារសំរាប់អតិថិជន
- សុខភាព
- ស្មោះត្រង់ ( មិនមានការបន្លំទម្ងន់)
- ប្រាក់ចំណេញត្រូវបានប្រើប្រាស់សំរាប់អភិវឌ្ឍន៍សង្គម ។